01022511

ឯកសារដើម

ORIGINAL DOCUMENT/DOCUMENT ORIGINAL

ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 29 / 08 / 2014

ម៉ោង (Time/Heure): 16:40

មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

E314/2

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

សាធារណៈ / Public

## អនុស្សរណៈអន្តរការិយាល័យ - អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៤

**ជូនចំពោះ:** ឯកឧត្តម គង់ ស្រ៊ឹម ប្រធានគណៈកម្មាធិការរដ្ឋបាលតុលាការ

**ចម្លងជូន:** លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ភាគីទាំងអស់នៅក្នុងសំណុំរឿង ០០២/០២

**ពី:** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ:** ការជូនដំណឹងអំពីសំណើរបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន ដើម្បីប្តឹងជំទាស់ដកចិត្តចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង ជំនួសឲ្យជម្រើសមួយផ្សេងទៀត

នៅថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៤ ក្រុមមេធាវីការពារក្តី ខៀវ សំផន បានដាក់សំណើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងផ្អាកកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០២/០២ រហូតដល់សាលក្រមនៅក្នុងសំណុំរឿង ០០២/០១ ចូលជាស្ថាពរ ហើយបញ្ហាទាំងឡាយផ្សេងទៀតដែលត្រូវបានលើកឡើងនៅក្នុងសំណុំរឿង ០០២/០១ ត្រូវបានអង្គជំនុំជម្រះតុលាការកំពូលដោះស្រាយរួចរាល់ជាមុនសិន (E314/1)។ ជាជម្រើសមួយទៀត ក្រុមមេធាវីការពារក្តីស្នើសុំប្តឹងដកចិត្តចៅក្រមដែលមានរាយនាមខាងក្រោមនេះចេញពីការជំនុំជម្រះក្រោយៗទៀតនៅក្នុងសំណុំរឿង ០០២។ ចៅក្រមទាំងនេះគឺ ចៅក្រមប្រធាន និល ណុន ចៅក្រម Silvia CARTWRIGHT ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE ចៅក្រម យូរ ឧត្តារា និងចៅក្រម Claudia FENZ។ សំណើសុំរបស់ ខៀវ សំផន បានធ្វើឡើងបន្ទាប់ពីក្រុមមេធាវីការពារក្តី នួន ជា បានជូនដំណឹងអំពីចេតនារបស់ពួកគេក្នុងការដាក់សំណើសុំប្តឹងដកចិត្តចៅក្រមមួយចំនួននៃអង្គជំនុំជម្រះសាលាដំបូង (E314.1) និងបន្ទាប់ពីមានសំណើសុំឲ្យគណៈកម្មាធិការរដ្ឋបាលតុលាការបង្កើតក្រុមប្រឹក្សាជំនុំជម្រះមួយ ដើម្បីវិនិច្ឆ័យទៅលើសំណើសុំរបស់

នួន ជា។ អនុស្សរណៈនេះមានគោលបំណងជូនជាដំណឹងដល់ឯកឧត្តមប្រធានអំពីសំណើសុំរបស់ ខៀវ សំផន (ឯកសារ E314/1) អនុលោមតាមវិធាន ៣៤(៦) នៃវិធានផ្ទៃក្នុង និងក្នុងករណីដែលសំណើសុំនេះអាចប៉ះពាល់ដល់សមាសភាពក្រុមប្រឹក្សាជំនុំជម្រះដែលគណៈកម្មាធិការរដ្ឋបាលតុលាការបង្កើតឡើង។